# ការស្វែងយល់ពី

# ច្បាប់ឥស្លាម

## الأحكام الأساسية

## កម្រិត ១



اعداد لجنة الترجمة
بالمركز الثقافي الحضاري
العربي- كمبوديا

(1)

# អារម្ភកថា

សេចក្ដីសរសើរទាំងឡាយគឺសម្រាប់អល់ឡោះម្ចាស់នៃពិភពទាំង ឡាយ និងសូមពរជ័យ សន្តិភាពកើតមាន ដល់អ្នកនាំសាររបស់អល់ឡោះ និងក្រុមគ្រួសារលោក ព្រមទាំងសហាហ្ពាត់ទាំងអស់របស់លោក។

ពិតប្រាកដណាស់មនុស្សជាច្រើនដោយសារការធ្វេសប្រហែស និង មិនបានយកចិត្តទុកដាក់លើក្បួនច្បាប់នៃសាសនាឥស្លាម រហូតដល់មិនបាន យល់ដឹងអំពីក្បួនច្បាប់ដែលជាប្រការចាំបាច់សម្រាប់ពួកគេ។ ដូច្នេះហើយ គណៈកម្មាធិការបកប្រែនៃអង្គការវប្បធម៌ អារ្យធម៌ កម្ពុជា-អារ៉ាប់ បានចាប់ផ្ដើម រៀបរៀងសៀវភៅនេះដើម្បីងាយស្រួលក្នុងការ សិក្សា យល់ដឹង អំពីក្បួនច្បាប់ ដែលជាប្រការចាំបាច់សម្រាប់អ្នកមូស្លីម ដែលក្នុងនោះ មានដូចជា : គោលគ្រឹះនៃ សាសនាឥស្លាម និង ជំនឿ ការយកទឹករ៉ូហ្ម(យកទឹកជម្រះកាយ) របៀបរបប ក្នុងការសឡាត (ថ្វាយបង្គំ)និងក្បួនច្បាប់ដទៃផ្សេងទៀត ដែលជាអត្ថបទ សម្រាយជាភាសា ខ្មែរ សម្រួលដល់ការអានសម្រាប់អ្នកដែលមិនចេះភាសាអារ៉ាប់ និងអមដោយរូបភាពងាយស្រួលក្នុងការអនុវត្ត។

សូមអល់ឡោះជាម្ចាស់ប្រទានពរជ័យដល់ក្រុមការងារយើងខ្ញុំ និង មិត្តអ្នកអានទាំងឡាយ ឱ្យទទួលបានជោគជ័យ សុវត្ថិភាព និងវិបុលភាព ជានិរន្តរ៍។

# បញ្ជីអត្ថបទ


| អត្ថបទ | ទំព័រ |
|---|---|
| មេរៀនទី១: គោលគ្រឹះនៃសាសនាឥស្លាម និងគោលគ្រឹះនៃជំនឿ | ០១ |
| ១ - គោលគ្រឹះនៃសាសនាឥស្លាម | ០១ |
| ២ - គោលគ្រឹះនៃជំនឿ | ០៤ |
| មេរៀនទី២: ការយកទឹកវ៉ូហ្ន(យកទឹកជម្រះកាយ) និងការងូតទឹក | ០៦ |
| ១ - ការយកទឹកវ៉ូហ្ន(យកទឹកជម្រះកាយ) | ០៦ |
| ២- ការជូតនៅលើស្បែកជើងខ្លុប និងស្រោមជើង | ១១ |
| ៣- ការងូតទឹក | ១៤ |
| ច្បាប់ដែលទាក់ទងនិងអ្នកមកឈាមរដូវឈាមជំងឺនិងឈាមសម្រាលកូនរួច | ១៧ |
| មេរៀនទី៣: ប្រតិបត្តិសឡាត និងការទន្ទេញ ជំពូកអាល់ហ្វាទីហះ | ២០ |
| ១- សារៈសំខាន់ និងគុណប្រយោជន៍នៃសឡាត | ២០ |
| ២- សឡាតហ្វារឌូ(ចំនួនរីកអាត់ និងពេលវេលារបស់វា) | ២១ |
| ៣- ជំពូកអាល់ហ្វាតីហះ(ទន្ទេញ) | ២៤ |
| មេរៀនទី៤: របៀបសឡាត និងការទន្ទេញតះយិត | ២៦ |
| ១- របៀបសឡាត | ២៦ |
| ២- តះយិត(ទន្ទេញ) | ៣៥ |
| តារាងការបួងសួង(ទូអា)ក្នុងពេលសឡាត | ៣៦ |
| មេរៀនទី៥: សល់វ៉ាតលើណាហ្គី | ៣៨ |
| មេរៀនទី៦: ជំពូកអាល់អៀខឡោស | ៣៩ |
| មេរៀនទី៧: ជំពូកអាល់អោសរ៍ និងអាល់ការសើរ | ៤១ |

## មេរៀនទី១

# គោលគ្រឹះនៃសាសនាឥស្លាម និងគោលគ្រឹះនៃជំនឿ

## ១ - គោលគ្រឹះនៃសាសនាឥស្លាម

គេស្ថាបនាសាសនាឥស្លាមនៅលើគោលគ្រឹះប្រាំយ៉ាង។ មិនអាចក្លាយជាអ្នកមូស្លីមទេលើលែងតែព្រមទទួលស្គាល់វា និងប្រតិបត្តិតាមវាយ៉ាងពេញលេញដោយមានជំនឿពិតប្រាកដ និងស្មោះស្ម័គ្រ។

អំពី កូនអូមើរ គាត់បាននិយាយថា រ៉សូលុលឡោះបានមានប្រសាសន៍ថា:

عَنْ ابْنِ عُمَرَ رَضِيَ اللهُ عَنْهُمَا : قَالَ قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ " بُنِيَ الْإِسْلَامُ عَلَى خَمْسٍ شَهَادَةِ أَنْ لَا إِلَهَ إِلاَّ اللهُ وَأَنَّ مُحَمَّدًا رَسُولُ اللهِ وَإِقَامِ الصَّلَاةِ وَإِيتَاءِ الزَّكَاةِ وَالْحَجِّ وَصَوْمِ رَمَضَانَ" (متفق عليه)

"គេស្ថាបនាឥស្លាមលើគោលគ្រឹះប្រាំយ៉ាងគឺ : ការធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវមានតែអល់ឡោះហើយមូហាំម៉ាត់គឺជារ៉សូល(អ្នកនាំសារ) របស់អល់ឡោះ ការប្រតិបត្តិសឡាត ការបរិច្ចាគហ្សាកាត់ ការធ្វើបុណ្យហាជ្ជី និង ការបួសខែរ៉ម៉ាឌន"។ (រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម)

## គោលគ្រឹះនៃសាសនាឥស្លាមគឺ

១- ពាក្យសច្ចាទាំងពីរ: (ខ្ញុំធ្វើសាក្សីថាគ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ ត្រឹមត្រូវមានតែអល់ឡោះ ហើយខ្ញុំធ្វើសាក្សីទៀតថា មូហាំម៉ាត់គឺជារ៉សូល(អ្នកនាំសារ)របស់ អល់ឡោះ។

២- ការប្រតិបត្តិសឡាត (ថ្វាយបង្គំ)

៣-ការបរិច្ចាគហ្សាកាត់(បង់មួយចំណែកតូចនៃទ្រព្យសម្បត្តិ)

៤- ការបួសក្នុងខែរ៉ម៉ាឌន

៥- ការធ្វើបុណ្យហាជ្ជ ចំពោះអ្នកដែលមានលទ្ធភាព។

## អត្ថន័យរបស់( أَشْهَدُ أَنْ لاَّ إِلَهَ إِلاَّ اللهُ )

ពិតប្រាកដណាស់គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវមានតែអល់ឡោះ ហើយទ្រង់សាកសមនឹងទទួលរាល់ការគោរពសក្ការៈទាំងអស់ អំពីការខ្លាច ការសង្ឃឹម ការប្រគល់ការទុកចិត្ត ការសុំឱ្យជួយ ការបួងសួង ការរ៉ូកុការស៊ូជោទ(ឱនលំទោន និងការបន្ទាបខ្លួន)-ល-។ អល់ឡោះទ្រង់ជាព្រះដ៏ពិតប្រាកដហើយរាល់ការគោរពសក្ការៈទៅចំពោះព្រះផ្សេងពីទ្រង់គឺមិនមែនជាព្រះ ពិតប្រាកដឡើយ។

ហើយមានរួមបញ្ចូលនៅក្នុងការសច្ចានេះការបដិសេធនិងទទួលស្គាល់។បដិសេធរាល់ការគោរពសក្ការៈដែលផ្សេងពី

អល់ឡោះទាំងអស់ ហើយទទួលស្គាល់រាល់ការគោរពសក្ការៈទាំងអស់ចំពោះអល់ឡោះតែម្នាក់គត់ ដោយគ្មានអ្នកចូលរួមជាមួយទ្រង់ឡើយ។

## អត្ថន័យរបស់ (أَشْهَدُ أَنَّ مُحَمَّداً رَّسُوْلُ)

ពិតប្រាកដណាស់មូហាំម៉ាត់គាត់ជាអ្នកនាំសាររបស់អល់ឡោះដែលពិតប្រាកដ។ ចាំបាច់ត្រូវប្រតិបត្តិតាមអ្វីដែលលោកបញ្ជាប្រើហើយជឿជាក់ រាល់ដំណឹងដែលលោកបានប្រាប់ ហើយជៀសឱ្យឆ្ងាយនូវអ្វីដែលលោកហាមឃាត់ ហើយយើងគោរពសក្ការៈទៅចំពោះអល់ឡោះ ទៅតាមក្បួនច្បាប់បានកំណត់។

## សំនួរពិចារណា:

១-តើពេលណាទើបបុគ្គលម្នាក់បានក្លាយជាអ្នកមូស្លីម?

២-តើជាអ្នកមូស្លីមត្រឹមត្រូវដែរឬទេ

បើគាត់ទទួលស្គាល់ការបួសក្នុងខែរ៉ម៉ាឌន និងប្រតិបត្តិហាជ្ជី តែគាត់មិនទទួលស្គាល់ការបរិច្ចាគហ្សាកាត់ (បង់មួយចំណែកតូចនៃទ្រព្យសម្បត្តិ)?

## ២ - គោលគ្រឹះនៃជំនឿ

### គោលគ្រឹះនៃជំនឿមាន៦យ៉ាង

គ្មាននណាម្នាក់អាចមានជំនឿពេញលេញនោះទេលើកលែងតែគេជឿចំពោះគោលគ្រឹះទាំងអស់នេះ។

អំពី អូម៉ើរ កូន អាល់ខត់តប បាននិយាយថា មានបុរសម្នាក់បានសួរ រ៉សូលុលឡោះអំពីជំនឿ? លោកបានឆ្លើយថា:

"الإيمان أن تؤمن بالله وملائكته وكتبه ورسله وباليوم الآخر وبالقدر خيره وشره" (رواه مسلم)

"ជំនឿនោះគឺ អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡើអ៊ីកាត់របស់ទ្រង់ បណ្តាគម្ពីរដែលទ្រង់បានបញ្ចុះមក បណ្តាអ្នកនាំសាររបស់ទ្រង់ ជឿចំពោះថ្ងៃបរលោក និងជឿចំពោះការកំណត់សំណាងល្អនិងអាក្រក់"។(រាយការណ៍ដោយ មូស្លីម)

### គោលគ្រឹះនៃជំនឿគឺ

១- ជឿចំពោះអល់ឡោះ

២- ជឿចំពោះម៉ាឡើអ៊ីកាត់(ពួកទេវតា)របស់ទ្រង់

៣- ជឿចំពោះបណ្តាគម្ពីររបស់ទ្រង់

៤- ជឿចំពោះបណ្តាណាហ្ពី(អ្នកនាំសារ)របស់ទ្រង់

៥- ជឿចំពោះថ្ងៃបរលោក

៦- ជឿចំពោះការកំណត់សំណាងល្អ និងអាក្រក់។

## សំនួរពិចារណា:

១-តើច្បាប់ឥស្លាមចែងយ៉ាងដូចម្តេចចំពោះជនណាដែល បដិសេធលើការធ្វើឱ្យ រស់ឡើងវិញបន្ទាប់ពីស្លាប់?

២-តើជាជំនឿត្រឹមត្រូវដែរឬទេសម្រាប់បុគ្គលម្នាក់ដែលជឿតែ ចំពោះអល់ឡោះនិងម៉ាឡើអ៊ីកាត់(ពួកទេវតា)របស់ទ្រង់ហើយ មិនជឿចំពោះបណ្តាណាហ្ពី(អ្នកនាំ សារ)របស់ទ្រង់នោះ?

## មេរៀនទី ២

# ការយកទឹកវ៉ូហ្ទុ( យកទឹកជម្រះកាយ ) និងការខ្ទតទឹក

## ១ - ការយកទឹកវ៉ូហ្ទុ(យកទឹកជម្រះកាយ)

### ១-១-គុណប្រយោជន៍នៃការយកទឹកវ៉ូហ្ទុ( យកទឹកជម្រះកាយ )

មានការរាយការណ៍ជាច្រើននៅក្នុងហាឌីសណាហ្គីដែលទាក់ទងនឹងគុណប្រយោជន៍នៃការយកទឹកវ៉ូហ្ទុ(យកទឹកជម្រះកាយ) ក្នុងនោះរ៉សូលុលឡោះបាន មានប្រសាសន៍ថា:

قال رسول الله صلى الله عليه وسلم : مَنْ تَوَضَّأَ ، فَأَحْسَنَ الْوُضُوءَ
خَرَجَتْ خَطَايَاهُ مِنْ جَسَدِهِ حَتَّى تَخْرُجَ مِنْ تَحْتِ أَظْفَارِهِ . (رواه مسلم)

“បុគ្គលណាយកទឹកវ៉ូហ្ទុដោយល្អត្រឹមត្រូវនោះ បាបកម្មរបស់គាត់នឹងចេញពីខ្លួនប្រាណរបស់គាត់ សូម្បីតែនៅក្រោមក្រចក”។ (រាយការណ៍ដោយ មូស្លីម)

### ១-២-របៀបយកទឹកវ៉ូហ្ទុ( យកទឹកជម្រះកាយ )

១- ខ្ញុំនៀត(ប៉ង)យកទឹកវ៉ូហ្ទុនិងចិត្តរបស់ខ្ញុំ

២- ខ្ញុំសូត្រ ពីសមីលឡើហ៍(بسم الله )

៣- ខ្ញុំលាងប្រអប់ដៃទាំងពីរបីដង



១-រូបភាពនៃការលាងប្រអប់ដៃ

៤- ខ្ញុំខ្ពុរមាត់បីដង

៥-ខ្ញុំស្រូបទឹកបញ្ចូលច្រមុះ និងញើសវាចេញវិញបីដង



២- រូបភាពនៃការខ្ពុរមាត់



៣-រូបភាពនៃការស្រូបទឹកបញ្ចូលច្រមុះ និងញើសវាចេញមកវិញ។

៦-ខ្ញុំលាងមុខបីដងចាប់ពីគល់សក់រហូតដល់ ក្រោមចង្ការ ហើយចាប់ពីត្រចៀក រហូតដល់ ត្រចៀកម្ខាងទៀត។ ហើយខ្ញុំលាងពុកចង្ការ និងស្បែកដែលនៅក្រោមវា ប្រសិនបើវាស្តើង ប្រសិនបើវាក្រាស់លាងពីលើវា ហើយឈ្លីចូលក្នុងវា។



៤- រូបភាពលាងមុខ



ខ្ញុំលាងមុខបីដងចាប់ពីគល់សក់រហូតដល់ក្រោមចង្ការហើយចាប់ពីត្រចៀករហូតដល់ត្រចៀកម្ខាងទៀត។

៧- ខ្ញុំលាងដៃទាំងពីររហូតដល់កែងដៃបីដង(កែងដៃវាគឺជាចន្លោះរវាងដើមដៃ និងកំភួនដៃ)



៥- រូបភាពលាងដៃ



ខ្ញុំលាងដៃទាំងពីររហូតដល់កែងដៃបីដង។

៨- ខ្ញុំជូតក្បាលមួយដងគត់ (ចាប់ផ្ដើមពីផ្នែកខាងមុខនៃក្បាល រហូតដល់ក្រោយបន្ទាប់មកត្រឡប់ មកវិញ។

៩- ខ្ញុំជូតត្រចៀកទាំងពីរ ដោយបញ្ចូលម្រាមដៃចង្អុលក្នុងត្រចៀក ហើយជូតខាងក្រៅដោយ មេដៃទាំងពីរ។

(ជូតក្បាលជាមួយត្រចៀកតែម្តងប៉ុណ្ណោះ។)



៦- រូបភាពជូតក្បាល



៧- រូបភាពជូតត្រជៀកទាំងពីរ

១០- ខ្ញុំលាងជើងទាំងពីររហូតដល់ភ្នែកគោល បីដង



៨- រូបភាពលាងជើងទាំងពីរ



ខ្ញុំលាងជើងទាំងពីររហូតដល់ភ្នែកគោល បីដង

## ១-៣-ប្រការដែលនាំឱ្យខូចការយកទឹកវ៉ូហ្ទុវាមានប្រាំ

១-អ្វីដែលចេញតាមទ្វារទាំងពីរ(មុខក្រោយ)ដូចជា ទឹកនោម លាមក ផោម ទឹកម៉ាហ្ស៊ី ទឹកវ៉ាទី(ទឹករំអិល)។

២-ចេញណាជីស(ធាតុកខ្វក់)ក្រៅពីទ្វាទាំងពីរដូចជាឈាម អាក្រក់ ទឹកនោម លាមក ឈាមច្រមុះច្រើន។

៣-បាត់បង់វិចារណញ្ញាណដូចជាគេងលង់លក់(ដែលមិន ដឹងខ្លួន) ឬ ឆ្កួត ឬសន្លប់ ឬស្រវឹង ឬដោយការប្រើថ្នាំ។

៤-កាន់ប្រដាប់ភេទ(មុខ ក្រោយ)ដោយផ្ទាល់។

៥-ហូបសាច់អូដ្ឋ។

## ១-៤-ប្រការដែលគេហាមមិនឱ្យអ្នកគ្មានទឹកវ៉ូហ្ទុធ្វើ

១-ប្រតិបត្តិសឡាត(ថ្វាយបង្គំ)

២-តវ៉ាហ្វ(ដើរជុំវិញកៈហ្ពះ)

៣-ប៉ះគម្ពីរគួរអានដោយផ្ទាល់

## សំនួរពិចារណា

១-បុរសម្នាក់បានយកទឹកវ៉ូហ្សួរួចហើយក៏បានគេងលក់បន្តិច តែគាត់នៅអង្គុយ តើវ៉ូហ្សួរបស់គាត់ខូចដែរឬទេ?

២-បុរសម្នាក់បានយកទឹកវ៉ូហ្សួរួចហើយក៏បានប៉ះប្រដាប់ភេទពីលើសំលៀកបំពាក់របស់គាត់ តើគាត់ត្រូវយកទឹកវ៉ូហ្សួម្តង ទៀតដែរឬទេ?

៣-បុរសម្នាក់បានយកទឹកវ៉ូហ្សួរួចហើយក៏បានហូបសាច់ពពែ តើគាត់ត្រូវយកទឹក វ៉ូហ្សួដើម្បីសឡាតដែរឬទេ?

៤-បុរសម្នាក់បានយកទឹកវ៉ូហ្សួដោយលាងជើងទាំងពីរហើយលាងមុខហើយជូតក្បាលបន្ទាប់មកលាងដៃទាំងពីររបស់គាត់ ចូររៀបរាប់កន្លែងដែលគាត់បានធ្វើខុស ពេលយកទឹកវ៉ូហ្សួ?

## ២- ការជូតនៅលើស្បែកជើងខ្លប និងស្រោមជើង

ស្បែកជើងដែលពាក់លើជើងទាំងពីរប្រសិនបើវាធ្វើអំពីស្បែកសត្វវាជាស្បែកជើងខ្លប។ប្រសិនបើមិនមែនធ្វើអំពីស្បែកសត្វទេដូចជាធ្វើអំពីរោមសត្វក្រណាត់និងក្រណាត់ធ្វើពីសសៃ

រុក្ខជាតិវាជាស្រោមជើង។ហើយស្រោមជើងក៏អាចជំនួសកន្លែងស្បែកជើងខ្លុបបានដែរ ប្រសិនបើវាបិទជិត។

### ២-១-ច្បាប់ដែលទាក់ទងនឹងការជូត

នៅពេលដែលមនុស្សបានពាក់ស្បែកជើងខ្លុប ឬស្រោមជើងហើយចង យកទឹកវ៉ូហ្ទុ ពិតណាស់គាត់អាចជូតនៅលើស្បែកជើងខ្លុប ឬស្រោមជើង ដោយអនុវត្ត តាមលក្ខខ័ណ្ឌខាងក្រោម:

១-ត្រូវពាក់វានៅពេលដែលមានទឹកវ៉ូហ្ទុ

២-ត្រូវឱ្យវានោះបិទជិតប្រអប់ជើងរហូតដល់ភ្នែកគោល

### ២-២-របៀបជូត

យកដៃទៅប៉ះទឹកឱ្យសើមហើយជូតនៅលើស្បែកជើងខ្លុប ឬស្រោមជើងដោយម្រាមដៃ។



៩- រូបភាពជូតលើស្បែកជើងខ្លុប និងស្រោមជើង

## ២-៣-ថេរវេលានៃការជូត

គេអនុញ្ញាត្តឱ្យជូតនៅលើស្បែកជើងខ្លប និងស្រោមជើងសម្រាប់ អ្នកវត្តមាន (មិនធ្វើដំណើរ) រយៈពេល ១ ថ្ងៃ ១ យប់ (២៤ម៉ោង)ហើយសម្រាប់អ្នកធ្វើដំណើរ រយៈពេល ៣ថ្ងៃ ៣យប់ (៧២ម៉ោង)។ហើយចាប់ផ្តើមរាប់ពីពេលដែលជូតដំបូង បន្ទាប់ពេលខូចទឹករ៉ូហ្ញ។

## ២-៤-ប្រការដែលនាំឱ្យខូចការជូត

១- ផុតពេលកំណត់

២- ប្រការដែលចាំបាច់ងូតទឹក(និងមានការបកស្រាយនៅខាងមុខ)

៣- ដោះស្បែកជើងខ្លប ឬស្រោមជើងចេញ

## សំនួរពិចារណា

១-បុរសម្នាក់បានយកទឹករ៉ូហ្ញ បន្ទាប់មកក៏ពាក់ស្រោមជើង ហើយក៏ដោះវាចេញវិញ ហើយក៏ពាក់វាម្តងទៀត តើច្បាប់អនុញ្ញាត្តឱ្យគាត់ជូតនៅលើវាទាំងពីរដែរ ឬទេ?

២-បុរសម្នាក់បានជូតលើស្បែកជើងខ្លបទាំងខាងលើ និង ខាងក្រោម តើអ្នកគួរ ប្រាប់គាត់ដូចម្តេច?

## ៣- ការងូតទឹក

### ៣-១-របៀបងូតទឹកដែលគ្រប់លក្ខណៈនិងពេញលេញ

១-ខ្ញុំនៀត(ប៉ង)ជម្រះកាយនៅក្នុងចិត្តរបស់ខ្ញុំ

២-ខ្ញុំសូត្រ ពីសមីលឡើហ៍ (بسم الله)

៣-ខ្ញុំលាងប្រអប់ដៃរបស់ខ្ញុំទាំងពីរបីដង

៤-ខ្ញុំលាងប្រដាប់ភេទរបស់ខ្ញុំ

៥-ខ្ញុំយកទឹកវ៉ូហ្ចូដូចយកទឹកវ៉ូហ្ចូសឡាត។ បន្ទាប់មកខ្ញុំលាងជើងទាំងពីររបស់ខ្ញុំ ហើយខ្ញុំក៏អាចទុកការលាងជើងនៅពេលចុងក្រោយនៃការងូតទឹកក៏បាន។ នៅពេលរួចរាល់ ខ្ញុំស្រោចទឹកលើក្បាលបីដងឱ្យសព្វដល់គល់សក់។

៦-ស្រោចទឹកលើខ្លួនឱ្យសព្វពេញរាងកាយចាប់ផ្ដើមពីផ្នែកខាងស្ដាំ បន្ទាប់មកខាងឆ្វេងជាមួយនឹងការដុះលាងត្រង់ឃ្លៀក ក្នុងត្រចៀក និង ផ្ចិត។ហើយក៏ដូច្នោះដែរត្រង់កន្លែងកន្លាក់ដែលចាំបាច់ត្រូវដុះលាង។

### ៣-២-របៀបងូតទឹកដែលគេទទួលយក

ខ្ញុំនៀត(ប៉ង)ជម្រះកាយបន្ទាប់មកសូត្រ(ពីសមីលឡើហ៍)ស្រោចទឹកលើខ្លួនឱ្យសព្វពេញរាងកាយ និងលាងក្នុងមាត់ និងច្រមុះ ដោយការខ្ពុរមាត់ និងស្រូបទឹកបញ្ចូលច្រមុះ។

## ៣-៣-ភាគព្វកិច្ចងូតទឹក

១-ចេញទឹកកាមពេលមានអារម្មណ៍ ដោយសារការរួមដំណេក ឬយល់សប្ត ឬផ្សេងពីនេះដូចជាការធ្វើដោយខ្លួនឯង និងការមើលរឿង។

២-ការជួបគ្នារវាងប្រដាប់ភេទទាំងពីរបុរសនឹងស្ត្រីទោះបីជាមិន ចេញទឹកកាមក៏ដោយ។

៣-មកឈាមរដូវ និងឈាមពេលសម្រាលកូនរួច។ហើយលក្ខខណ្ឌ របស់វាគឺត្រូវងូតទឹកបន្ទាប់ពីអស់ឈាម។

៤-អ្នកចូលឥស្លាមថ្មី។

៥-ស្លាប់ដែលមិនមែនស្លាប់ សាហ៊ីទ (ស្លាប់ដោយធ្វើសង្គ្រាម ក្នុងផ្លូវ អល់ឡោះ)នៅក្នុងសង្គ្រាម។

## ៣-៤-អ្វីដែលគេហាមឃាត់មិនឱ្យអ្នកមានជូនុប(អ្នកចេញទឹកកាម )ប្រព្រឹត្ត

១-ប្រតិបត្តិសឡាត

២-តវ៉ាហ្វ(ដើរជុំវិញកៈហ្បះ)

៣-ប៉ះគម្ពីរគួរអាន

៤-សូត្រគម្ពីរគួរអាន

៥-ស្ថិតនៅក្នុងម៉ាស្ជិទលើកលែងតែយកទឹកវ៉ូហ្ទុ

## ៣-៥-ប្រការដែលគេហាមឃាត់មិនឱ្យអ្នកមកឈាមរដូវ និងឈាមពេលសម្រាលកូនរួចប្រព្រឹត្ត

១-ប្រតិបត្តិសឡាត(មិនចាំបាច់សឡាតសារឡើងវិញទេ)
២-បួស(ចាំបាច់បួសសងវិញប្រសិនបើបួសរ៉ម៉ាឌន)
៣-តវ៉ាហ្វ(ដើរជុំវិញក:ហ្ពះ)
៤-ស្ថិតនៅក្នុងម៉ាស្ជីទ
៥-ប៉ះគម្ពីរគួរអាន (គេអនុញ្ញាតឱ្យសូត្រគួរអាន និងប៉ះគួរអានដោយ មានអ្វីទ្រាប់ដូចជាស្រោមដៃ)
៦-រួមដំណេក

### សំនួរពិចារណា

១-បុរសម្នាក់រួមដំណេកជាមួយប្រពន្ធរបស់គាត់បន្ទាប់មកគាត់ចង់សូត្រគួរអាន តើចាំបាច់ត្រូវធ្វើដូចម្តេច?

២-ស្ត្រីម្នាក់មកឈាមរដូវបន្ទាប់មកក៏អស់ឈាមរដូវវិញមុនពេលសឡាត តើគាត់ត្រូវធ្វើដូចម្តេច?

# ច្បាប់ដែលទាក់ទងនិងអ្នកមកឈាមរដូវ ឈាមជំងឺ និងឈាមសម្រាលកូនរួច

## ១-ឈាមរដូវ

**និយមន័យ:** វាគឺជាឈាមធម្មជាតិដែលមានលាយពណ៌ខ្មៅខាប់ដែលចេញពី ប្រដាប់ភេទស្ត្រី។

**ពេលវេលាចេញ:** ចាប់ពីអាយុ ៩ឆ្នាំរហូតដល់ពេលអស់វានៅអាយុ ៥០ឆ្នាំ ជាទូទៅ។

**រយៈពេល:** តិចបំផុត ១ថ្ងៃ១យប់។ ជាទូទៅ ៦ឬ៧ថ្ងៃជារៀងរាល់ខែ។ ច្រើនបំផុត ១៥ថ្ងៃ។

**កាតព្វកិច្ច:** ងូតទឹកក្រោយពេលអស់វា និង បួសសង។

**ប្រការហាមឃាត់:**

១-ប្រតិបត្តិសឡាត

២-បួស

៣-តវ៉ាហ្វ(ដើរជុំវិញកៈហ្ពះ)

៤-ប៉ះគួរអានដោយគ្មានអ្វីទ្រាប់

៥-ស្ថិតនៅក្នុងម៉ាស្ជីទ

៦-រួមដំណេក។

**ក្បួនច្បាប់:**

១-ហាមឃាត់មិនឱ្យលែងលះក្នុងពេលហ្នឹងឡើយ

២-ប្រព្រឹត្តកិច្ចការរាល់ថ្ងៃបានធម្មតា
៣-អាចគេងជាមួយប្តីបានដោយមិនរួមរ័ក្សឡើយ។

## ២-ឈាមជំងឺ

**និយមន័យ:** វាគឺជាឈាមពណ៌ក្រហមដែលនូវបន្តការចេញហើយវាមានភាព ខុសប្លែកពីឈាមរដូវ ដូចជាពណ៌ លក្ខណ: និងក្លិនរបស់វា។

**ពេលវេលាចេញ:** មិនមានពេលវេលាច្បាស់លាស់ឡើយ មានហើយ វាជាឈាម ដែលផ្តលផល់ប៉ះពាល់ដល់ស្ត្រី។

**រយ:ពេល:** មិនមានរយ:ពេលច្បាស់លាស់ឡើយ។

**កាតព្វកិច្ច:** យកទឹកវ៉ូហ្ញុរាល់ពេលសឡាត។

**ប្រការហាមឃាត់:**

មិនមានអ្វីហាមឃាត់សម្រាប់អ្នកមកឈាមជំងឺឡើយ

**ក្បួនច្បាប់:** ត្រូវដាក់ប្រដាប់ការពារឈាមកុំឱ្យប្រឡាក់សំលៀកបំពាក់ ឬម៉ាស្ជីទ នៅពេលដែលគាត់ចង់តវ៉ាហ្វនៅក:ហ្ពះ ឬសឡាតនៅក្នុងម៉ាស្ជីទ។

## ៣-ឈាមពេលសម្រាលកូនរួច

**និយមន័យ:** ឈាមដែលចេញពីអ្នកមានផ្ទៃពោះ នៅពេលសម្រាលកូន ឬមុន ពេលសម្រាល។

**ពេលវេលាចេញ:** នៅពេលសម្រាលកូន ឬមុនពេលសម្រាល ១ថ្ងៃ ឬ២ថ្ងៃ ឬ៣ថ្ងៃ។

**រយៈពេល:** ច្រើនបំផុត ៤០ថ្ងៃ ហើយមិនកំណត់រយៈពេលតិចបំផុតឡើយ។

**កាតព្វកិច្ច:**

១-ងូតទឹកក្រោយពេលអស់ឈាម

២-បួសសង។

**ប្រការហាមឃាត់:**

១-ប្រតិបត្តិសឡាត

២-បួស

៣-តវ៉ាហ្វ(ដើរជុំវិញកៈហ្ពះ)

៤-ប៉ះគួរអានដោយមិនមានអ្វីទ្រាប់

៥-ស្ថិតនៅក្នុងម៉ាស្ជិទ

៦-រួមដំណេក។

**ក្បួនច្បាប់:**

១-ប្រព្រឹត្តកិច្ចការរាល់ថ្ងៃបានធម្មតា

២-អាចគេងជាមួយប្តីបានដោយមិនរួមរ័ក្សឡើយ។

## មេរៀនទី ៣

# ប្រតិបត្តិសឡាត និងការទន្លេញដំពូករាល់ហ្វាទីហះ

### ១- សារៈសំខាន់ និងគុណប្រយោជន៍នៃសឡាត

សម្រាប់សឡាតគឺមានសារៈសំខាន់ខ្លាំងបំផុតនៅក្នុងសាសនាឥស្លាម ដូចជា:

- គោលគ្រឹះទី២នៃគោលគ្រឹះសាសនាឥស្លាមទាំងប្រាំ
- សរសរទ្រូងនៃសាសនាឥស្លាម ដែលវា មិនអាចឈរបានទេលើកលែងតែមានវា(សឡាត)។
- ជាកាតព្វកិច្ចដំបូងបំផុតដែលអល់ឡោះបានដាក់លើខ្ញុំរបស់ទ្រង់។
- ការគោរពសក្ការៈហ្វារឌូ(កាតព្វកិច្ច)ជារៀងរាល់ថ្ងៃវាគឺជាការភ្ជាប់ខ្លួនអ្នកមូស្លីមជាមួយនឹងម្ចាស់របស់គាត់។
- អត្តសញ្ញាណ ដ៏ច្បាស់លាស់មួយនៃ អត្តសញ្ញាណរបស់សាសនាឥស្លាម។
- គេជំនុំជំរះនៅលើវាដំបូងគេបង្អស់នៅថ្ងៃបរលោក។ ប្រសិនបើវាល្អប្រសើរ ទង្វើផ្សេងទៀតក៏ល្អប្រសើរដែរ តែប្រសិនបើវា មិនល្អ ទង្វើផ្សេងទៀតក៏មិនល្អដែរ។

ពិតប្រាកដណាស់មានការរាយការណ៍ជាច្រើននៅក្នុងហាឌីសអំពីគុណប្រយោជន៍នៃសឡាត ក្នុងនោះមានហាឌីសអាពីហ៊ូរ៉យរ៉ោះ បាននិយាយថា: ខ្ញុំបានលឺរ៉សូលុលឡោះបានមានប្រសាសន៍ថា៖

عَنْ أَبِي هُرَيْرَةَ قال سَمِعت رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ ، يَقُولُ: "أَرَأَيْتُمْ لَوْ أَنَّ نَهْرًا بِبَابِ أَحَدِكُمْ يَغْتَسِلُ مِنْهُ كُلَّ يَوْمٍ خَمْسَ مَرَّاتٍ ، هَلْ يَبْقَى مِنْ دَرَنِهِ شَيْءٌ ؟ قَالُوا : لَا يَبْقَى مِنْ دَرَنِهِ شَيْءٌ ، قَالَ : فَذَلِكَ مَثَلُ الصَّلَوَاتِ الْخَمْسِ ، يَمْحُو اللَّهُ بِهِنَّ الْخَطَايَا " (متفق عليه)

"តើពួកអ្នកយល់យ៉ាងណាដែរ ប្រសិនបើមានទន្លេមួយនៅមុខទ្វារផ្ទះរបស់ពួកអ្នកហើយគាត់ងូតទឹកនោះមួយថ្ងៃ៥ដងរាល់ថ្ងៃ តើកំអែលរបស់គាត់អាចនៅសេសសល់ដែរឬទេ? "ពួកគាត់ឆ្លើយថា:"កំអែលរបស់គាត់មិនសេសសល់ទេ"លោកបានមានប្រសាសន៍ថា:"នោះគឺដូចជាការសឡាតទាំង៥ពេលដែរ ដែលអល់ឡោះជំរុះចោលនូវបាបកម្មទាំងឡាយ"។

(រាយការណ៍ដោយអាល់ពូខរី និងមូស្លីម)

## ២- សឡាតហ្វារឌូ(ចំនួនរ៉ីកអាត់ និងពេលវេលារបស់វា)

អល់ឡោះបានដាក់ការតព្វកិច្ចលើខ្ញុំបំរើរបស់ទ្រង់ឱ្យប្រតិបត្តិសឡាត៥ពេល ក្នុងមួយថ្ងៃ មួយយប់។ វាគឺ **សឡាតហ្វាជរ៍ (ស៊ូពុះ) សឡាតស៊ូហ៊្វ សឡាត អាសើរ សឡាតម៉ោគរិប សឡាតអ៊ីសា** ហើយក៏ដាក់កាតព្វកិច្ចឱ្យប្រតិបត្តិវាក្នុងពេល

កំណត់ច្បាស់លាស់។ដូចដែលអល់ឡោះបានមានព្រះបន្ទូលថា៖

قال الله تعالى "إِنَّ الصَّلَاةَ كَانَتْ عَلَى الْمُؤْمِنِينَ كِتَابًا مَّوْقُوتًا"(النساء ١٠٣)

"ពិតប្រាកដណាស់សឡាតជាកាតព្វកិច្ចមួយទៅលើបណ្ដាអ្នកមានជំនឿ ដែល មានពេលវេលាកំណត់យ៉ាងច្បាស់លាស់"។

(អាន់នីសាក ១០៣)

## ការបង្ហាញអំពីឈ្មោះសឡាតហ្វារឌូ ចំនួនរ៉ឹកអាត់ និងពេលវេលារបស់វានៅក្នុងតារាងខាងក្រោម:

| តារាងរ៉ឹកអាត់ និងពេលវេលាសឡាតហ្វារឌូ | | |
|---|---|---|
| សឡាត | រ៉ឹកអាត់ | ពេលវេលា |
| សឡាតហ្វាជរ៍(ស៊ូប៉ោះ) | ពីររ៉ឹកអាត់ | ចាប់ពីសេតរុណរះរហូតដល់ថ្ងៃរះ |
| សឡាតស៊ូហ៊្វុទ | បួនរ៉ឹកអាត់ | ចាប់ពីថ្ងៃជ្រេរបន្តិចរហូតដល់ស្រមោលអ្វីម្យ៉ាងស្មើនិងខ្លួនរបស់វា |
| សឡាតអាសើរ | បួនរ៉ឹកអាត់ | ចាប់ពីពេលស្រមោលអ្វីម្យ៉ាងស្មើនិងខ្លួនរបស់វារហូតដល់ថ្ងៃលិច |
| សឡាតម៉ោគរិប | បីរ៉ឹកអាត់ | ចាប់ពីថ្ងៃលិចរហូតដល់ពន្លឺពណ៌ក្រហមលិចបាត់ |
| សឡាតអ៊ីសា | បួនរ៉ឹកអាត់ | ចាប់ពីពន្លឺពណ៌ក្រហមលិចបាត់រហូតដល់ពាក់កណ្ដាលយប់ |

## សំនួរពិចារណា

១-បុរសម្នាក់ប្រតិបត្តិសឡាត ស៊ូហ៊្វ មុនពេលថ្ងៃជ្រេរ តើសឡាតរបស់ គាត់ត្រឹមត្រូវដែរឬទេ?

២-ស្ត្រីម្នាក់បានគេងនៅពាក់កណ្តាលយប់ បន្ទាប់មកគាត់ក្រោកនៅពេលថ្ងៃរះ តើអ្នកប្រាប់គាត់ដូចម្តេច?

៣-តើអ្នកដឹងអំពីគុណប្រយោជន៍របស់សឡាត់ផ្សេងពីអ្វីដែលបានរៀបរាប់ ក្នុងសៀវភៅនេះដែរឬទេ?

## ៣- ជំពូកអាល់ហ្វាតីហះ(ទន្ទេញ)

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

**ប៊ីសមីលឡើហ៊ី រ៉ោះម៉ានីរ រ៉ហ៊ីម**

(ក្នុងនាមអល់ឡោះមហាសប្បុរស មហាអាណិតស្រឡាញ់)

الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ

**អាល់ហាំទូ លីលឡើហ៊ី រ៉ប់ពីល អាឡើមីន**

(រាល់ការសរសើរ គឺចំពោះអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់)

الرَّحْمَنِ الرَّحِيمِ

**អាររ៉ោះម៉ានីរ រ៉ហ៊ីម**

(ជាម្ចាស់មហាសប្បុរស មហាអាណិតស្រឡាញ់)

مَالِكِ يَوْمِ الدِّينِ

**ម៉ាលីគី យៅមីទ ទីន**

(ជាស្ដេច(គ្រប់គ្រង)នៃថ្ងៃជំនុំជំរះ(បរលោក))

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

**អ៊ីយ៉ាកើ ណាក់ពូទូ វ៉ាអ៊ីយ៉ាកើ ណាសតាអ៊ីន**

(ចំពោះទ្រង់តែមួយគត់ដែលពួកយើងគោរពសក្ការៈ ហើយ ចំពោះទ្រង់តែមួយគត់ដែលពួកយើងសុំឱ្យជួយ)

اهدِنَا الصِّرَاطَ الْمُسْتَقِيمَ

**អុីហាទីនុស ហ្សីរ៉ត្ឋល មុ៉សតាគីម**

(សូមទ្រង់មេត្តាចង្អុលបង្ហាញដល់ពួកយើងនូវមាគ៌ា ដ៏ត្រឹមត្រូវផងចុះ)

صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلاَ الضَّالِّينَ

**ហ្សីរ៉តល ឡើហ្សីណា អាន់អាំតា អាឡៃហុីម ហ្គយរីល ម៉ោគទូប៊ី អាឡៃហុីម វ៉ាឡត់ ហ្គោលលីន**

(គឺមាគ៌ា របស់បណ្ដាអ្នកដែលទ្រង់បានប្រទាននៀកម៉ាត់ ដល់ពួកគេ ពុំមែនជា (មាគ៌ា)អ្នកដែលត្រូវគេខឹងសម្បា និងពុំមែន ជា(មាគ៌ា)ពួកដែលវង្វេងឡើយ)។

មេរៀនទី ៤

# របៀបសឡាត និងការទន្លេញតះយិត

## ១- របៀបសឡាត

### មុនពេលសឡាត

**នៅពេលដែលខ្ញុំចង់សឡាត ខ្ញុំត្រូវ:**

-ជ្រះស្អាតពី ហាដីសធំ និងហាដីសតូច

-ជម្រះខ្លួនប្រាណ សំលៀកបំពាក់ និងទីកន្លែងសម្រាប់សឡាត

-បិទបាំងអៅរ៉ោះ

-ត្រូវច្បាស់លាស់ថា ដល់ពេលសឡាត (ពេលវេលាសឡាតបានរៀបរាប់ពីមុន)

-តម្រង់គីបឡះ វាគឺកៈហ្ពះ

-នៀត(ប៉ង):វាគឺការតាំងចិត្តលើការគោរពសក្ការៈអ្វីមួយច្បាស់លាស់។

-ឈរបើមានលទ្ធភាព



## ប្រតិបត្តិសឡាត

**បន្ទាប់មកចាប់ផ្តើមប្រតិបត្តិសឡាត ដូចខាងក្រោម:**

១-ខ្ញុំតឹកហ្បៀរ៉តេលអះរ៉ម ដោយសូត្រថា (الله أكبر )
(អល់ឡរហ្ញូអឹកពើរ) មើលទៅកាន់កន្លែងស៊ូជោទ។

២-លើដៃទាំងពីររបស់ខ្ញុំនៅពេលតឹកហ្បៀរ៉តុលអះរ៉ម រហូតដល់ស្មាទាំងពីរ ឬ ដល់ត្រចៀក។

២-តឹកហ្បៀរ៉តាលអះរ៉ម
(الله أكبر )
(អល់ឡរហ្ញូអឹកពើរ)





រូបភាពលើកដៃស្មើរនឹងត្រចៀក



៣-ដាក់ដៃទាំងពីររបស់ខ្ញុំលើដើមទ្រូងរបស់ខ្ញុំ ខាងស្តាំដាក់លើខាងឆ្វេង។

៤-សូត្រទូអារអ៊ីសតីហ្វតះ

سُبْحَانَكَ اللَّهُمَّ وَبِحَمْدِكَ وَتَبَارَكَ اسْمُكَ وَتَعَالَى جَدُّكَ وَلاَ إِلَهَ غَيْرُكَ

ស៊ុបហាណាកល់ឡរហុំម៉ា វ៉ាប៊ីហាំ ទីកើ វ៉ាតាពើរ៉កាសម៉ូកើ
វ៉ាតាអាឡើ ដើទទូកា វ៉ាឡើអ៊ីឡើហើ ហ្គុយរ៉ូកើ

សូត្រទូអារអ៊ីសតីហ្វតះ
سُبْحَانَكَ اللَّهُمَّ وَبِحَمْدِكَ وَتَبَارَكَ اسْمُكَ وَتَعَالَى جَدُّكَ وَلاَ إِلَهَ غَيْرُكَ
ស៊ុបហាណាកល់ឡរហុំម៉ា វ៉ាប៊ីហាំ ទីកើ
វ៉ាតាពើរ៉កាសម៉ូកើ វ៉ាតាអាឡើ ជើទទូកើ
វ៉ាឡើអ៊ីឡើហើ ហ្គុយរ៉ូកើ





ដាក់ដៃលើដើមទ្រូង

៥-បន្ទាប់មកខ្ញុំសូត្រ

أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ

**អាអ៊ូហ្សូពីលឡើហីមីណាសស្ហៃតណានីរ៉ជីម**

بِسْمِ اللَّهِ الرَّحْمَنِ الرَّحِيمِ

**ប៊ីសមីលឡើហ៊ី រ៉ោះម៉ានីរ រ៉ហ៊ីម**

ហើយសូត្រជំពូក**អាល់ហ្វាតីហះ** ហើយបន្ទាប់ពីសូត្រចប់ខ្ញុំសូត្រ (آمين)(អាមីន)លឺៗនៅក្នុងសឡាតសូត្រលឺ និងតិចៗក្នុងពេលសឡាតសូត្រតិច។

៦-បន្ទាប់មកខ្ញុំសូត្រអ្វីដែលងាយស្រួលអំពីគួរអាន

៧-ខ្ញុំរ៉ូកុដោយសូត្រតឹកប្បៀរ

-លើកដៃទាំងពីររហូតដល់ស្មា ឬត្រចៀក

-ដាក់ក្បាលរបស់ខ្ញុំឱ្យស្មើនឹងខ្នង ហើយភ្នែករបស់ខ្ញុំ សម្លឹងមើលកន្លែង ស៊ូជោទ។

-ដាក់ដៃទាំងពីររបស់ខ្ញុំលើជង្គង់ហើយញែកម្រាមដៃចេញពីគ្នា

-ខ្ញុំរ៉ូកុឱ្យបាននឹងនរហើយសូត្រ ( سُبْحَانَ رَبِّيَ الْعَظِيم ) **(ស៊ុបហាណារ៉បពីយ៉ាលអាហ្ស៊ីម)** ចំនួនបីដងឬច្រើនជាងនេះ។




៨-ខ្ញុំងើបក្បាលឡើងពីរ៉ូក

-លើកដៃរបស់ខ្ញុំរហូតដល់ស្មា ឬត្រចៀក

-សូត្រថា( سَمِعَ اللهُ لِمَنْ حَمِدَهُ ) **(សើមីអល់ឡហ្លីម៉ាន់ហាមីដះ)**

ប្រសិនបើខ្ញុំជាអ៊ីម៉ាំ ឬសឡាតម្នាក់ឯង

-ហើយខ្ញុំសូត្រនៅពេលដែលឈរត្រង់ថា ( رَبَّنَا وَلَكَ الْحَمْدُ ) **(រ៉ប់ពើណាវ៉ាឡើកើលហាំ)**

រូបភាពងើបឡើងពីរ៉ូក

سَمِعَ اللهُ لِمَنْ حَمِدَهْ

សើមីអល់ឡហ៊្វ លីម៉ាន់ហាមីដះ

رَبَّنَا وَلَكَ الْحَمْدُ

រ៉ប់ពើណាវ៉ាឡើកើលហាំ




៩-ខ្ញុំស៊ូជោទដោយសូត្រតឹកពៀរត្រូវស៊ូជោទនៅលើប្រាំពីរអវយវៈ

-ថ្ងាស និងច្រមុះ   -ដៃទាំងពីរ   -ជង្គងទាំងពីរ

-ចុងជើងទាំងពីរ ហើយប្រអប់ជើងបែមុខទៅទិសគីបឡះ

ហើយសូត្រថា ( سُبْحَانَ رَبِّي الأَعْلَى ) **(ស៊ុបហាណារ៉ប់ពីយ៉ាលអាក់ឡើ)** បីដងឬច្រើនជាងនេះ។

រូបភាពស៊ូជោទ



( سُبْحَانَ رَبِّي الأَعْلَى )

( ស៊ុបហាណារ៉ប់ពីយ៉ាលអាក់ឡើ )

ចំនួនបីដង

១០-ខ្ញុំងើបក្បាលឡើងមកវិញដោយសូត្រតឹកពៀរ
-ហើយខ្ញុំដាក់ជើងឆ្វេងរាប់ស្មើហើយអង្គុយលើវា
-ហើយខ្ញុំបញ្ឈរជើងស្តាំ
-ហើយខ្ញុំដាក់ដៃទាំងពីរលើកំភ្លៅឬជង្គង់
-ហើយខ្ញុំសូត្រ( رَبِّ اغْفِرْلِي ) **(រ៉ប់ពីគហ្វៀរលី)**
-ហើយខ្ញុំអង្គុយឱ្យនឹងនរ

រូបភាពអង្គុយពីខាងមុខ



រូបភាពអង្គុយពីខាងក្រោយ



១១-ខ្ញុំស៊ូជោទលើកទីពីរដោយសូត្រតឹកពៀរ ហើយខ្ញុំប្រតិបត្តិវាដូចដែលខ្ញុំបានប្រតិបត្តិនៅក្នុងស៊ូជោទទីមួយ។

១២-បន្ទាប់មកខ្ញុំងើបឈរដើម្បីប្រតិបត្តិរីកអាត់ទី២ដោយសូត្រតឹកពៀរ ហើយខ្ញុំប្រតិបត្តិវា ដូចដែលខ្ញុំបានប្រតិបត្តិនៅក្នុងរីកអាត់ទី១ដែរ។

១៣-បន្ទាប់មកខ្ញុំអង្គុយបន្ទាប់ពីងើបពី ស៊ូជោទទី២ ហើយខ្ញុំសូត្រតះឃិត និង សល់វ៉ាត លើណាហ្ពី។

១៤-បន្ទាប់មកខ្ញុំឱ្យសាឡាមទៅខាងស្តាំ ហើយខាងឆ្វេងដោយសូត្រ

(السلام عليكم ورحمة الله)

**(អាសសាឡាម៉ូអាឡៃគុំវ៉ារ៉សម៉ាតុលឡហ៍)**

ដើម្បីបញ្ចប់ការសឡាតប្រសិនបើជាសឡាតពីររីកអាត់។

រូបភាពឱ្យសាឡាមទៅខាងស្តាំ



រូបភាពឱ្យសាឡាមទៅខាងឆ្វេង



១៥-ប្រសិនបើវាជាសឡាត ៣រឹកអាត់ ឬបួនរឹកអាត់ ខ្ញុំនឹងងើបឈរបន្ទាប់ពីសូត្រតះយិតរួច ដោយសូត្រតឹកពៀរ លើកដៃទាំងពីរ ហើយខ្ញុំប្រតិបត្តិវា ដូចដែលខ្ញុំបានប្រតិបត្តិនៅក្នុងរឹកអាត់ទី១ លើកលែងតែក្នុងពេលឈរ ខ្ញុំសូត្រតែជំពូក ហ្វាតីហះប៉ុណ្ណោះ។

១៦-ខ្ញុំអង្គុយតះយិតចុងក្រោយក្នុងសឡាតដែលមានបីរឹកអាត់ ឬបួនរឹកអាត់ ដោយ**អង្គុយតាវ៉ារុក**។

**អង្គុយតាវ៉ារុក**

គឺខ្ញុំបញ្ឈរជើងស្តាំរបស់ខ្ញុំ ហើយតម្រង់ម្រាមជើងទៅទិសគីបឡះ ហើយដាក់ជើងឆ្វេងរាប់ស្មើនៅខាងក្រោមកជើងស្តាំហើយខ្ញុំអង្គុយនៅលើដី។




រូបភាពអង្គុយតាវ៉ារុក

## សំនួរពិចារណា

១-បុរសម្នាក់គាត់សឡាតអាសើរ ហើយគាត់បានឈរសឡាតរឹកអាត់ទី១បន្ទាប់មកគាត់ស៊ូជោទដោយបោះបង់រ៉ូកុ តើសឡាតរបស់គាត់ត្រឹមត្រូវដែរឬទេ?

២-បុរសម្នាក់សឡាតដោយបែរមុខទៅទីក្រុងម៉ាឌីណះ
តើសឡាតរបស់គាត់ដូចម្ដេចដែរ?

៣-បុរសម្នាក់សឡាតមុនពេលដល់ពេលវេលារបស់វា
តើសឡាតរបស់គាត់ដូចម្ដេចដែរ?

## ២- តះយិត(ទន្ទេញ)

នៅពេលដែលខ្ញុំងើបក្បាលឡើងពីស៊ូជោទនៅរឹកអាត់ទីពីរក្នុងសឡាត ខ្ញុំអង្គុយហើយសូត្រតះយិត ហើយខ្ញុំបានសូត្រវា នៅក្នុងពេលអង្គុយចុងក្រោយ បន្ទាប់ពីរឹកអាត់ទី៣ ឬទី៤ ដោយសូត្រថា:

التَّحِيَّاتُ لِلَّهِ وَالصَّلَوَاتُ وَالطَّيِّبَاتُ السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ
وَبَرَكَاتُهُ السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللَّهُ
وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

អាត់តាហ៊ីយ៉ាតូលីលឡើហ វ៉ាសហ្សរឡើវ៉ាតូ វ៉ាតតុយយីពើត
អាសសាឡាម៉ូ អាឡៃកើ អៃយូហាន់ណាពីយូ
វ៉ារ៉ោះម៉ាតុលឡរហ៊ី វ៉ាពើរ៉កើទុះ អាសសាឡាម៉ូ អាឡៃណា
វ៉ាអាឡើ អ៊ីពើទីលឡើហ៊ីសហ្សរលីហ៊ីន អាស់ហើទូ
អាលឡើអ៊ីឡើ ហើអ៊ីលលុលឡោះ វ៉ាអាស់ហើទូ
អាន់ណាម៉ូហាំម៉ាទ័ន អាប់ទូហ៊ូ វ៉ារ៉សូលុះ។

# តារាងការបួងសួង( ទូអា )ក្នុងពេលសឡាត

| ឈ្មោះការបួងសួង (ទូអា) | កន្លែងសូត្រត្រូវវាក្នុងពេលសឡាត | ឃ្លាបួងសួង |
|---|---|---|
| តឹកពៀរ | ពេលចាប់ផ្ដើមចូលសឡាត និងពេលផ្លាសប្ដូពីរ៉ូកុនមួយទៅរ៉ូកុនមួយទៀត | អល់ឡរហ៊ូអឹកពើរ |
| ទូអាអ៊ីសតីហ្វតះ | បន្ទាប់ពីតឹកហ្បៀរចូលសឡាត | ស៊ុបហាណាកលឡូរហ៊ុំម៉ា វ៉ាប៊ី ហាំទីកើ វ៉ាតាពើរ៉កាសម៉ូកើ វ៉ាតាអាឡើ ជើទទូកើ វ៉ាឡើអ៊ុឡើហើ ហ្គុយរ៉ូកើ |
| អាតតាអៅ វ៉ាហ្ស | មុនពេលសូត្រជំពូកហ្វាតីហះ | អាអ៊ូហ្សូពីលឡើហីមីណាសស្តែតណានីររ៉ជីម |
| ពាសម៉ាឡះ | មុនពេលសូត្រជំពូកហ្វាតីហះ | ប៊ីសមីលឡើហ៊ីរ រ៉ោះម៉ានីររ៉ហ៊ីម |
| ជំពូកហ្វា តីហះ | ពេលឈរ | បានបកស្រាយរួចហើយ |
| អាតតាកមីន | ក្រោយពេលសូត្រជំពូកហ្វាតីហះចប់ | អាមីន |
| ហ្សីកៀរពេលរ៉ូកុ | ពេលរ៉ូកុ | ស៊ុបហាណារ៉បពីយ៉ាលអាហ្សីម |
| អាតតាស មៀក | ពេលងើបពីរ៉ូកុ | សើមីអល់ឡរហ៊ូលីម៉ាន់ហាមីដះ |

| | | |
|---|---|---|
| អាតតៈមីទ | ឈរក្រោយពេលរ៉ូកុ | រ៉ប់ពើណាវ៉ាឡើកើលហាំ |
| ហ្ស៊ីកៀរពេលស៊ូជោទ | ពេលស៊ូជោទ | ស៊ុបហាណារ៉ប់ពីយ៉ាលអាក់ឡើ |
| ហ្ស៊ីកៀរពេលអង្គុយ | ពេលអង្គុយរវាងស៊ូជោទទាំងពីរ | រ៉ប់ពីគហ្វៀរលើ |
| តៈឃិត | ពេលអង្គុយលើកទី១ក្រោយពេលចប់រឹកអាត់ទី២<br>និងពេលអង្គុយចុង ក្រោយ | បានបកស្រាយរួចហើយ |
| សឡើវ៉ាតលើណាពី | ពេលអង្គុយតៈឃិតចុងក្រោយ | នឹងមានការបកស្រាយនៅខាងមុខ |
| អាតតាស លីម | ពេលបញ្ចប់សឡាត | អាសសាឡាម៉ូអាឡៃគុំវ៉ារ៉សម៉ាតុលឡហ៍ |

## មេរៀនទី ៥

# សលវ៉ាតលើណាហ្គី

### ១- សល់វ៉ាតលើណាហ្គី(ទន្ទេញ)

ក្រោយពេលសូត្រតះយិតចប់ ខ្ញុំសល់វ៉ាតលើណាហ្គី និងក្រុមគ្រួសាររបស់ លោក ដោយសូត្រថា

اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَعَلَى آلِ مُحَمَّدٍ كَمَا صَلَّيْتَ عَلَى إِبْرَاهِيمَ وَعَلَى آلِ إِبْرَاهِيمَ إِنَّكَ حَمِيدٌ مَجِيدٌ ، و بَارِكْ عَلَى مُحَمَّدٍ وَعَلَى آلِ مُحَمَّدٍ كَمَا بَارَكْتَ عَلَى إِبْرَاهِيمَ وَعَلَى آلِ إِبْرَاهِيمَ إِنَّكَ حَمِيدٌ مَجِيدٌ

អល់ឡរហ៊ុំម៉ា សល់លី អាលើ ម៉ូហាំម៉ាត់ វ៉ាអាលើ អាលី ម៉ូហាំម៉ាត់ កើម៉ា សល់ឡៃតា អាលើ អ៊ីពរ៉ហ៊ីម វ៉ាអាលើ អាលី អ៊ីពរ៉ហ៊ីម អ៊ីនណាកើ ហាមីទុំ ម៉ាជីទ វ៉ាពើរិក អាលើ ម៉ូហាំម៉ាត់ វ៉ាអាលើ អាលី ម៉ូហាំម៉ាត់ កើម៉ា ពើរឹកតា អាលើ អ៊ីពរ៉ ហ៊ីម វ៉ាអាលើ អាលី អ៊ីពរ៉ហ៊ីម អ៊ីនណាកើ ហាមីទុំ ម៉ាជីទ។

## មេរៀនទី ៦

# ជំពូកអាល់អៀខឡាស

## ១- ជំពូកអាល់អៀខឡាស

بسم الله الرحمن الرحيم

**ប៊ីសមីលឡើហ៊ីរ រ៉ោះម៉ានីរ រ៉ហ៊ីម**

(ក្នុងនាមអល់ឡោះមហាសប្បុរស មហាអាណិតស្រឡាញ់)

قُلْ هُوَ اللَّهُ أَحَدٌ

**គុលហ៊្វើរ៉ុលឡរហ៊្វើអាហាទ**

(ចូរអ្នក(មូហាំម៉ាត់)ពោលថាៈ អល់ឡោះគឺជាម្ចាស់តែមួយគត់)

اللَّهُ الصَّمَدُ

**អល់ឡរហ៊្វើសសម៉ាទ**

(អល់ឡោះ គឺជាអ្នកដែលត្រូវគេពឹងពាក់)

لَمْ يَلِدْ وَلَمْ يُولَدْ

**ឡាំយ៉ាឡីទវ៉ាឡាំយ៉ូឡាទ**

(ទ្រង់មិនបានប្រសូតបុត្រឡើយ ហើយទ្រង់ក៏មិនត្រូវគេប្រសូតដែរ)

وَلَمْ يَكُن لَّهُ كُفُوًا أَحَدٌ

**វ៉ាឡាំយ៉ាគុលឡើហ៊ូកូហ្វូវ៉ាន់អាហាទ**

(ហើយគ្មាននរណាម្នាក់ប្រៀបប្រដូចនឹងទ្រង់ឡើយ)

## មេរៀនទី ៧

# ជំពូកអាល់អាសរ៏ និងអាល់កាទសើរ

## ១- ជំពូកអាល់អាសរ៏(ទន្ទេញ)

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

**ប៊ីសមីលឡើហ៊ិរ រ៉ោះម៉ានីរ រ៉ហ៊ីម**

(ក្នុងនាមអល់ឡោះមហាសប្បុរស មហាអាណិតស្រឡាញ់)

وَالْعَصْرِ

**វ៉ាលអាសរ៏**

(អល់ឡោះស្បថនឹងពេលវេលា)

إِنَّ الْإِنْسَانَ لَفِي خُسْرٍ

**អ៊ីនណាលអ៊ីនសើណាលើហ្វីខូសរ៏**

(ពិតប្រាកដណាស់ មនុស្សលោកគឺស្ថិតក្នុងភាពខាតបង់)

إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ وَتَوَاصَوْا بِالْحَقِّ وَتَوَاصَوْا بِالصَّبْرِ

**អ៊ីលឡាលឡើហ្សីណា អាម៉ានូ វ៉ាអាមីលុស សលីហាតី វ៉ាតាវ៉ាសៅពីលហុកគី វ៉ាតាវ៉ាសៅពីសស៊បរ៍**

(លើកលែងតែបណ្តាអ្នកដែលមានជំនឿ និងបានសាងអំពើល្អត្រឹមត្រូវ និងបានផ្តែផ្តាំគ្នាឱ្យប្រកាន់ខ្ជាប់នូវការពិត និងបានផ្តែផ្តាំ គ្នាឱ្យមានការអត់ធ្មត់ ប៉ុណ្ណោះ)

## ២- ជំពូកអាល់កាវសើរ(ទន្លេញ)

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

**ប៊ីសមីលឡើហ៊ីរ រ៉ោះម៉ានីរ រ៉ហ៊ីម**

(ក្នុងនាមអល់ឡោះមហាសប្បុរស មហាអាណិតស្រឡាញ់)

إِنَّا أَعْطَيْنَاكَ الْكَوْثَرَ

**អ៊ីនណាអាក់តុយណាកិលកៅសើរ**

(ពិតប្រាកដណាស់ យើងបានប្រទានឱ្យអ្នក(មូហាំម៉ាត់) នូវអាល់កាវសើរ(ទន្លេមួយនៅក្នុងឋានសួគ៌))

فَصَلِّ لِرَبِّكَ وَانْحَرْ

**ហ្វាសល់លីលីរ៉ប់ប៊ីកើវ៉ាន់ហើរ**

(ដូច្នេះ ចូរអ្នកសឡាត និងសំឡេះសត្វដើម្បីម្ចាស់របស់អ្នកចុះ)

إِنَّ شَانِئَكَ هُوَ الْأَبْتَرُ

**អ៊ីនណាសើណីអាកើហ្វាល់អាប់តើរ**

(ពិតប្រាកដណាស់ អ្នកដែលស្អប់ខ្ពើមអ្នក(មូហាំម៉ាត់) គេនឹងត្រូវកាត់ផ្តាច់ ពីផលល្អ(ទាំងនៅក្នុងលោកិយ និងបរលោក))

**ចប់**

اعداد لجنة الترجمة

بالمركز الثقافي الحضاري العربي- كمبوديا